**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

# របាយការណ៍សង្ខេបស្តីពីការងារប្រយុទ្ធទប់ស្កាត់ការរីករាលដាល និងស្ថានភាព មេរោគអេដស៍ និងជំងឺអេដស៍ នៅកម្ពុជា ឆ្នាំ២០២៥

**ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

**ក្នុងទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ ថ្ងៃទី១ ខែធ្នូ ឆ្នាំ២០២៥**

**ក្រោមប្រធានបទ «យកឈ្នះការរំខាន បរិវត្តកម្មឆ្លើយតបនឹងជំងឺអេដស៍»**

ថ្ងៃចន្ទ ១១កើត ខែមិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

សាលសន្និសីទចតុមុខ, ថ្ងៃទី១ ខែធ្នូ ឆ្នាំ២០២៥

- *សូមគោរពឯកឧត្តម **សុខ ចិន្ដាសោភា** ឧបនាយករដ្ឋមន្ត្រី តំណាងដ៏ខ្ពង់ខ្ពស់ **សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា***
- *សូមគោរព ឯកឧត្តម លោកជំទាវ សមាជិក សមាជិកាពរាជរដ្ឋាភិបាល*
- ***លោកស្រី** Patricia Ongpin នាយិកាកម្មវិធីរួមអង្គការសហប្រជាជាតិស្តីពីមេរោគអេដស៍/ជំងឺអេដស៍(UNAIDS)ប្រចាំកម្ពុជា ឡាវ និងម៉ាឡេស៊ី*
- *ឯកឧត្តម លោកជំទាវ លោក លោកស្រី តំណាងក្រសួង ស្ថាប័ន អង្គការជាតិ និងអន្តរជាតិ ទាំងអស់ជាទីរាប់អាន!*

តាងនាមថ្នាក់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំមានកិត្តិយស និងសេចក្ដីសោមនស្សរីករាយក្រៃលែង ដែលបានរៀបចំទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ ១ ធ្នូ ឆ្នាំ២០២៥ ក្រោមប្រធានបទ «**យកឈ្នះការរំខាន បរិវត្តកម្មឆ្លើយតបនឹងជំងឺអេដស៍**» ដ៏មហោឡារិកនាពេលនេះ។

ជាបឋម ខ្ញុំសូមសម្តែងនូវគារវកិច្ចដ៏ឧត្តុង្គឧត្តមចំពោះឯកឧត្តម **សុខ ចិន្ដាសោភា** ឧបនាយករដ្ឋមន្ត្រី តំណាងដ៏ខ្ពង់ខ្ពស់ **សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលបានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍នាពេលនេះ។

ជារៀងរាល់ឆ្នាំ ក្នុងនាមរាជរដ្ឋាភិបាល អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍តែងរៀបចំការប្រារព្ធទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ថ្ងៃទី១ ខែធ្នូ ជាទៀងទាត់។ ការប្រារព្ធទិវានេះធ្វើឡើងក្នុងគោលបំណងបង្ហាញការប្តេជ្ញាចិត្តដ៏មុតស្រួចរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការប្រយុទ្ធស្កាត់ការរាលដាលមេរោគអេដស៍និងជំងឺអេដស៍។ ក្នុងនោះ យើងរំឭកពីការផ្តល់នូវការគាំទ្រដល់អ្នកផ្ទុកមេរោគអេដស៍ រំឭកនូវការសោកស្តាយចំពោះអ្នកស្លាប់ដោយសារជំងឺអេដស៍ ព្រមទាំងក្រើនរំឭកដល់ប្រជាពលរដ្ឋទូទាំង

ប្រទេសឱ្យចងចាំពីគ្រោះថ្នាក់នៃការឆ្លងមេរោគអេដស៍ ដើម្បីឈានទៅបញ្ចប់ការឆ្លងរីករាលដាលមេរោគអេដស៍។ ទន្ទឹមនឹងនេះ យើងលើកកម្ពស់ការយល់ដឹងអំពីជំងឺអេដស៍ ដោយបង្ហាញពីសារៈសំខាន់នៃចំណេះដឹងស្តីពីវិធានការបង្ការនិងគ្រប់គ្រងជំងឺអេដស៍។ មកដល់ពេលនេះ អេដស៍នៅតែជាជំងឺមួយដែលគំរាមកំហែងដល់សុខភាពសាធារណៈ ដែលទាមទារឱ្យបន្តការយកចិត្តទុកដាក់បន្ថែមទៀតពីសំណាក់រាជរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និងដៃគូពាក់ព័ន្ធទាំងអស់។

ប្រធានបទជាសកល «**យកឈ្នះការរំខាន បរិវត្តកម្មឆ្លើយតបនឹងជំងឺអេដស៍**» គឺជាកាលានុវត្តភាពថ្មីមួយដើម្បីបង្ហាញពីផលប៉ះពាល់លើការឆ្លើយតបទៅនឹងមេរោគអេដស៍និងជំងឺអេដស៍ ដោយកត្តានានារួមមាន ការកាត់បន្ថយថវិកាជំនួយអន្តរជាតិ ការយល់ដឹងរបស់យុវវ័យ ការផ្លាស់ប្តូររបៀបរស់នៅ ការរីកចម្រើននៃបច្ចេកវិទ្យា ក៏ដូចជាដើម្បីបង្ហាញនូវការប្តេជ្ញាចិត្តរួមគ្នាប្រកបដោយចីរភាពភាពធន់របស់ប្រទេសក្នុងជំហរដ៏រឹងមាំការពារសមិទ្ធផលដែលសម្រេចបាន និងជំរុញការឆ្លើយតបនឹងមេរោគអេដស៍ឆ្ពោះទៅសម្រេចគោលដៅដែលបានកំណត់។ នៅឆ្នាំ២០២៥ ការធ្លាក់ចុះនៃថវិកាជំនួយកំពុងគំរាមកំហែងដល់វឌ្ឍនភាពនៃការឆ្លើយតបនឹងមេរោគអេដស៍និងជំងឺអេដស៍ ដែលពិភពលោករួមគ្នាសម្រេចបានជាច្រើនទសវត្សរ៍កន្លងមក។ សេវាបង្ការមេរោគអេដស៍ដឹកនាំដោយសហគមន៍ដែលធ្វើការផ្ទាល់ជាមួយអ្នកផ្ទុកមេរោគអេដស៍ និងក្រុមប្រជាជនគន្លឹះ កំពុងត្រូវបានកាត់បន្ថយសកម្មភាពខណៈពេលដែលការកើនឡើងនៃច្បាប់ផ្តន្ទាទោស ដែលដាក់ទោសលើទំនាក់ទំនងនៃការស្រឡាញ់ភេទដូចគ្នា អត្តសញ្ញាណយេនឌ័រនៅប្រទេសមួយចំនួន និងការប្រើប្រាស់គ្រឿងញៀនកំពុងពង្រីកឧបសគ្គ ដល់ការទទួលបានសេវាអប់រំ ការធ្វើតេស្ត ការថែទាំព្យាបាលមេរោគអេដស៍ និងជំងឺអេដស៍។

## ឯកឧត្តម លោកជំទាវ និងអង្គពិធីទាំងមូល

កម្ពុជាតែងតែអនុវត្តស្របតាមគោលនយោបាយ និងគោលដៅយុទ្ធសាស្ត្ររបស់អង្គការសហប្រជាជាតិ(UNAIDS) មានជាអាទិ៍ បង្គោលចរឆ្ពោះទៅគោលដៅសូន្យបី (សូន្យការឆ្លងមេរោគអេដស៍ថ្មី សូន្យការរើសអើង និងសូន្យការស្លាប់ដោយសារជំងឺអេដស៍) នៅឆ្នាំ២០១៥ រួមនឹងគោលដៅ ៩៥-៩៥-៩៥ (៩៥%នៃអ្នកផ្ទុកមេរោគអេដស៍បានដឹងពីស្ថានភាពផ្ទុកមេរោគអេដស៍របស់ខ្លួន ៩៥% នៃអ្នកដែលដឹងស្ថានភាពផ្ទុកមេរោគអេដស៍ បានទទួលការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ និង៩៥%នៃអ្នកដែលបានទទួលការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ មានបន្ទុកមេរោគអេដស៍កម្រិតទាប) នៅឆ្នាំ២០៣០។ គោលនយោបាយជាតិបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍សម្រាប់ឆ្នាំ២០២៣-២០២៨របស់រាជរដ្ឋាភិបាលបានដាក់ចេញឱ្យអនុវត្តក្នុងកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នាថ្ងៃទី១៥ ខែ មីនា ឆ្នាំ២០២៤ អនុលោមទៅនឹងយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ នៃរាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភាក្នុងការលើកកម្ពស់សុខភាព និងសុខុមាលភាពប្រជាជន។

ព្រះរាជាណាចក្រកម្ពុជា សម្រេចបានលទ្ធផលល្អគួរឱ្យកត់សម្គាល់ លើការងារឆ្លើយតបនឹងមេរោគអេដស៍ដែលមានទទួលស្គាល់ពីសកលលោក។

**ឯកឧត្តម លោកជំទាវ និងអ្នកចូលរួមក្នុងអង្គពិធីទាំងមូល!**

នាឱកាសដ៏វិសេសវិសាលនេះ ខ្ញុំសូមជម្រាបជូន **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ព្រមទាំងអង្គពិធីទាំងមូលនូវស្ថានភាពនៃការរីករាលដាល និងសមិទ្ធផលនៃការឆ្លើយតបនឹងមេរោគអេដស៍និងជំងឺអេដស៍មួយចំនួនដូចតទៅ៖

- នៅឆ្នាំ២០២៤ កម្ពុជាសម្រេចបាន
  - ៩២-១០០-៩៨ ជៀបនឹងគោលដៅ៩៥-៩៥-៩៥
  - ចំនួនអ្នកឆ្លងថ្មីមេរោគអេដស៍មាន១ ២០០ករណី បានថយចុះពី១៤ ០០០ នៅឆ្នាំ១៩៩៧
  - ចំនួនអ្នកស្លាប់ដោយសារជំងឺអេដស៍មាន១ ០០០ករណី បានថយចុះពី៤ ៧០០ករណី នៅឆ្នាំ២០០៣។
- អត្រាគ្របដណ្តប់កម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន(PMTCT) បានកើនពី ៩៣,២% នៅឆ្នាំ២០២៣ ទៅ៩៧,២% នៅឆ្នាំ២០២៤។
- អត្រាឆ្លងមេរោគអេដស៍ពីម្តាយទៅកូនក៏បានធ្លាក់ចុះពី៨,៤% ក្នុងឆ្នាំ២០២៣ មកនៅត្រឹមតែ៦,៩% ក្នុងឆ្នាំ២០២៤។
- នៅត្រីមាសទី៣ ឆ្នាំ២០២៥ មានអ្នកផ្ទុកមេរោគអេដស៍កំពុងទទួលការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ចំនួន៧១ ៧១៦នាក់ នៅតាមសេវាព្យាបាលជំងឺអេដស៍ចំនួន៧៤កន្លែងទូទាំងប្រទេស។
- នៅឆ្នាំ២០២៥នេះ ក្រសួងសុខាភិបាលបានដាក់ឱ្យដំណើរការសេវា PrEPចាក់ ដោយប្រើឱសថកាបូតេក្រាវៀ(Cabotegravir) ឬហៅថាCAB-PrEP ដែលអាចបង្ការការឆ្លងមេរោគអេដស៍រហូតដល់រយៈពេល២ខែ និងកងមានជាតិថ្នាំDapivirine ដាក់ក្នុងទ្វារមាស ដើម្បីបង្ការការឆ្លងមេរោគអេដស៍ ក្នុងចំណោមស្ត្រីប្រឈមខ្ពស់(ឬហៅកាត់ថា DVR-PrEP)
- គិតត្រឹមចុងខែកញ្ញា ឆ្នាំ២០២៥នេះ មានសេវាPrEP ចំនួន៥២ទីតាំង នៅតាមមន្ទីរពេទ្យមណ្ឌលសុខភាព មានចំនួន៣៦ទីតាំង និងមណ្ឌលសំចតមានចំនួន១៦ទីតាំង(អង្គការតាមសហគមន៍) ក្នុង១៦ រាជធានី ខេត្ត។
- គិតត្រឹមដំណាច់ខែកញ្ញា ឆ្នាំ២០២៥នេះ មានអតិថិជន ដែលជាក្រុមប្រឈមនឹងការឆ្លងមេរោគអេដស៍ ចំនួន៤៣ ៧៩០នាក់ បានទទួលសេវា PrEP ដែលក្នុងនោះ មានPrEP ចាក់(CAB-PrEP) ចំនួន៣២៥នាក់។
- នៅត្រីមាសទី៣ ឆ្នាំ២០២៥ ប្រជាជនគន្លឹះចំនួន៤៣ ៧៩០នាក់ បានចុះឈ្មោះទទួលសេវា PrEP ត្រូវជា៦៨,៣% នៃគោលដៅចំនួន៦៤ ០៨៣នាក់។
- ការស្លាប់ដោយសារជំងឺអេដស៍ ក៏មានការថយចុះជាបន្តបន្ទាប់ផងដែរ ដែលតាមការប៉ាន់ស្មានអ្នកស្លាប់មានប្រមាណជាង១ ៣០០នាក់ នៅឆ្នាំ២០២៣ មកនៅត្រឹមប្រមាណជាង១ ០០០នាក់នាឆ្នាំ២០២៤ កន្លងទៅនេះ។
- នៅត្រីមាសទី៣ ឆ្នាំ២០២៥ អ្នកផ្ទុកមេរោគអេដស៍ចំនួន៥៣ ៨២១នាក់ ស្មើនឹង៧៥% នៃអ្នកផ្ទុកមេរោគអេដស៍ចំនួន៧១ ៧១៦នាក់អ្នកដែលមកទទួលសេវាថែទាំព្យាបាល បានទទួល

បណ្ណមូលនិធិសមធម៌សុខាភិបាល(ម.ស.ស.) នៅតាមមូលដ្ឋានសុខាភិបាលនៅទូទាំង២៥ រាជធានី ខេត្ត។

- នៅខែកក្កដា ឆ្នាំ២០២៥ ប្រជាជនគន្លឹះប្រមាណ១៥ ៤៥៤ ត្រូវជា៩,២% បានទទួលបណ្ណមូលនិធិសមធម៌សុខាភិបាល(ម.ស.ស.)។
- គិតត្រឹមត្រីមាសទី១ ឆ្នាំ២០២៥ មូលនិធិជាតិជំនួយសង្គម បានផ្តល់ប្រាក់ឧបត្ថម្ភជូនដល់អ្នកផ្ទុកមេរោគអេដស៍ មកពីគ្រួសារក្រីក្រដែលមានប័ណ្ណសមធម៌ សម្រាប់កម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារចំនួន៤៥៩៤នាក់ ដែលចំណាយអស់ថវិកាចំនួន ៣៣៨ ២១២ ០០០ រៀល ស្មើនឹង៨៤ ៥៥៣ដុល្លារអាមេរិក។
- នៅឆ្នាំ២០២៤កន្លងមកនេះ ពុំមានការរាយការណ៍ពីការមាក់ងាយ និងរើសអើងពីខាងក្រៅ ខណៈដែលកាលពីនៅឆ្នាំ២០១៩ ការរើសអើងបដិសេធមិនផ្តល់ការងារប្រមាណ២% និងការបំពានជាពាក្យសម្តីមានប្រមាណ២%។ អ្វីដែលជាការគួរកត់សម្គាល់ ការមាក់ងាយ និងរើសអើងដោយខ្លួនឯង ជាពិសេសអារម្មណ៍ខ្មាសអៀនខ្លួនឯងនៅតែជាបញ្ហាគួរឱ្យព្រួយបារម្ភនៅឡើយដោយនៅឆ្នាំ២០១៩ មានប្រមាណ៦២,៧% ។

## ៦.អនុសាសន៍ គោលនយោបាយ និងអន្តរាគមន៍គន្លឹះ

ក្នុងគោលបំណងឱ្យការធ្វើអន្តរាគមន៍ទាំងឡាយ បានទទួលជោគជ័យ ធានាចីរភាពនិងភាពធន់ក្នុងការឆ្លើយតបនឹងមេរោគអេដស៍និងជំងឺអេដស៍ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ តាមរយៈកិច្ចប្រជុំពេញអង្គលើកទី២ ឆ្នាំ២០២៥ បានដាក់ចេញនូវសកម្មភាពគន្លឹះមួយចំនួនដូចខាងក្រោម៖

១- គ្រប់ក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្តត្រូវបន្តជំរុញការផ្សព្វផ្សាយឱ្យបានទូលំទូលាយ តាមរយៈកិច្ចប្រជុំ ផ្សព្វផ្សាយ វគ្គបណ្តុះបណ្តាល សិក្ខាសាលា វេទិកានានាដើម្បីបញ្ជ្រាបការយល់ដឹងអំពីហានិភ័យមេរោគអេដស៍និងជំងឺអេដស៍ ការមាក់ងាយ រើសអើង ដោយទាក់ទាញនិងលើកទឹកចិត្តដល់ប្រជាជនទូទៅ ជាពិសេសប្រជាជនគន្លឹះមកទទួលសេវាធ្វើតេស្តរកមេរោគអេដស៍ ថែទាំព្យាបាលឱ្យបានទាន់ពេលវេលា ទូលំទូលាយ និងតាមលទ្ធភាព។

២- គ្រប់រដ្ឋបាលរាជធានី ខេត្តត្រូវគាំទ្ររៀបចំគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ឱ្យបានចប់សព្វគ្រប់១០០% នាដំណាច់ឆ្នាំ២០២៥។

៣- អភិបាលនៃគណៈអភិបាលរាជធានី ខេត្តទាំងអស់ត្រូវប្រើប្រាស់ថវិកា៨០លានរៀល ៦០លានរៀល ៤០លានរៀល ដែលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានវិភាជជូនជារៀងរាល់ឆ្នាំលើការងារអេដស៍ ឱ្យអស់លទ្ធភាព និងមានប្រសិទ្ធភាពខ្ពស់។

៤- អភិបាលនៃគណៈអភិបាលរាជធានី ខេត្តទាំងអស់ណែនាំជួយសម្រួលឱ្យគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍រាជធានី ខេត្ត ដោយមានកិច្ចសហការជាមួយអង្គការសង្គមស៊ីវិល និងបណ្តាញជាដៃគូ មន្ទីរពាក់ព័ន្ធ(ផែនការ ទេសចរណ៍ សុខាភិបាល) និងបេឡាជាតិសន្តិសុខសង្គម ជំរុញប្រជាជនគន្លឹះបម្រើការក្នុងសេវាកម្សាន្តទេសចរណ៍ មានជាអាទិ៍ បុរសរួមភេទជាមួយបុរស (MSM) អ្នកបំប្លែងភេទ (TG) ស្ត្រីបម្រើក្នុងសេវាកម្សាន្ត (EW) មកធ្វើតេស្តរកមេរោគអេដស៍ ពិនិត្យព្យាបាលជំងឺកាមរោគ និងប្រើប្រាស់សេវាបង្ការការ

ចម្លងមេរោគអេដស៍នានា ព្រមទាំងពន្លឿនការរៀបចំចុះបញ្ជីផ្តល់បណ្ណមូលនិធិសមធម៌សុខាភិបាល(ម.ស.ស.)ដល់ប្រជាជនគន្លឹះ ឱ្យបានយ៉ាងឆាប់រហ័ស និងបានទូលំទូលាយ។

៥- អភិបាលនៃគណៈអភិបាលរាជធានី ខេត្តទាំងអស់ត្រូវណែនាំរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់លើកផែនការសកម្មភាពឆ្លើយតបនឹងមេរោគអេដស៍ និងប្រើប្រាស់ថវិកាតាមសារាចរអន្តរក្រសួងលេខ០០៧សហវ.ស.រ.អហក ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៥ ស្តីពីការគ្រប់គ្រង ការចាត់ចែង និងការកំណត់មុខសញ្ញាចំណាយថវិកាសេវាសង្គម និងអនាម័យបរិស្ថាន នៃមូលនិធិក្រុង ស្រុក និងមូលនិធិឃុំ សង្កាត់ ដើម្បីទទួលបាននូវប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព និងចីរភាព។

៦- ក្រសួងសុខាភិបាលបន្តពង្រីកសេវាធ្វើតេស្តរកមេរោគអេដស៍ សេវាបង្ការមុនពេលប្រព្រឹត្តប្រឈមនឹងការឆ្លងមេរោគអេដស៍(PrEP) សេវាបង្ការក្រោយពេលប្រព្រឹត្តប្រឈមនឹងការឆ្លងមេរោគអេដស៍(PEP) និងលើកទឹកចិត្តការប្រើប្រាស់ស្រោមអនាម័យឱ្យមានប្រសិទ្ធភាពជាប្រចាំដល់ក្រុមគោលដៅ ព្រមទាំងខិតខំទប់ស្កាត់ការឆ្លងមេរោគអេដស៍ពីម្តាយទៅកូនឱ្យមានប្រសិទ្ធភាពខ្ពស់។

៧- ក្រសួងសុខាភិបាលបន្តពង្រឹង ពង្រីកសេវាថែទាំព្យាបាល អ្នកផ្ទុកមេរោគអេដស៍ឱ្យមានប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពខ្ពស់។

៨- គ្រប់ក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្តត្រូវផ្តល់របាយការណ៍នៃការអនុវត្តថវិកាឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំឱ្យបានទៀងទាត់។

ឆ្លៀតក្នុងឱកាសដ៏វិសេសវិសាលនេះ ខ្ញុំសូមអំពាវនាវនូវការគាំទ្របន្ថែមទៀតពីរាជរដ្ឋាភិបាលកាកបាទក្រហមកម្ពុជា និងដៃគូអភិវឌ្ឍទាំងអស់ ទាំងផ្នែកស្មារតី ហិរញ្ញវត្ថុ បច្ចេកទេស ដើម្បីឱ្យយើងរក្សាចីរភាព ភាពជន់ក្នុងការអនុវត្តគោលនយោបាយជាតិបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍សម្រាប់ឆ្នាំ២០២៣-២០២៨ទទួលបានជោគជ័យ។ ជាមួយគ្នានេះ ខ្ញុំសូមអំពាវនាវជាថ្មីដល់ប្រជាពលរដ្ឋកម្ពុជាទាំងអស់ សូមប្តេជ្ញាចិត្តមោះមុតចូលរួមជាមួយអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ដូចខាងក្រោម៖

- សូមយុវវ័យទាំងអស់កុំឆាប់ប្រឡូកនឹងការរួមភេទ ហើយត្រូវចាកចេញឱ្យឆ្ងាយពីគ្រឿងញៀនដែលជាកត្តាប្រឈមខ្ពស់នឹងការឆ្លងមេរោគអេដស៍
- សូមយុវវ័យទាំងអស់សិក្សាស្វែងយល់ដឹងពីបញ្ហាសុខភាពបន្តពូជឱ្យបានទូលំទូលាយ ដើម្បីថែទាំសុខភាពឱ្យបានល្អ
- សូមស្ត្រីមានផ្ទៃពោះទាំងអស់ទៅទទួលយកការធ្វើតេស្តរកមេរោគអេដស៍។ បើមានលទ្ធផលតេស្តវិជ្ជមាន ត្រូវប្រញាប់ស្វែងរកសេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនឱ្យបានឆាប់រហ័ស នៅតាមមណ្ឌលសុខភាព ឬមន្ទីរពេទ្យរដ្ឋនានា នៅទូទាំងប្រទេស
- សូមអ្នកដែលមានការប្រព្រឹត្តប្រឈមនឹងការឆ្លងមេរោគអេដស៍ត្រូវភ្លាមៗ ប្រញាប់ទៅស្វែងរកការធ្វើតេស្តឈាមរកមេរោគអេដស៍ឱ្យបានឆាប់រហ័សនៅតាមមណ្ឌលសុខភាព មន្ទីរពេទ្យរដ្ឋ ឬបណ្តាញអង្គការសង្គមស៊ីវិល ដើម្បីឈានទៅទទួលបានសេវាថែទាំព្យាបាលទាន់ពេលវេលា។
- សូមអ្នកដែលបានដឹងខ្លួនថាមានផ្ទុកមេរោគអេដស៍ទាំងអស់ ប្រញាប់ទៅទទួលការថែទាំព្យាបាលឱ្យបានឆាប់រហ័ស និងគោរពវេជ្ជបញ្ជាឱ្យបានខ្ជាប់ខ្ជួន ដើម្បីការពារការស្រុតចុះសុខភាព

និងចៀសវាងការកើតនូវភាពស៊ាំរបស់មេរោគអេដស៍ទៅនឹងឱសថប្រឆាំងមេរោគអេដស៍ ដែលជាមូលហេតុនៃមរណភាពដោយសារជំងឺអេដស៍ និងសូមកុំបន្តចម្លងមេរោគអេដស៍ដល់អ្នកដទៃទៀត

- សូមចាត់ទុកអ្នកផ្ទុកមេរោគអេដស៍ជាជនរងគ្រោះដែលត្រូវចូលរួមលុបបំបាត់រាល់ទម្រង់នៃការរើសអើង និងមាក់ងាយពួកគាត់ និងត្រូវផ្តល់ការគាំទ្រគ្រប់លទ្ធភាព
- រាល់ការឆ្លើយតបនឹងមេរោគអេដស៍ និងអ្នកជំងឺអេដស៍ទាំងអស់ត្រូវតែឈរលើគោលការណ៍សមធម៌ សមភាព និងសិទ្ធិមនុស្ស។

**ឯកឧត្តម លោកជំទាវ និងអង្គពិធីទាំងមូល**!

តាងនាមអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ខ្ញុំសូមសម្តែងនូវកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅបំផុតចំពោះ**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន** ប្រធានកាកបាទក្រហមកម្ពុជា ដែលតែងតែផ្តល់ការគាំទ្រជានយោបាយ និងយុទ្ធសាស្ត្រ ដល់ការឆ្លើយតបនឹងការរីករាលដាលមេរោគអេដស៍។ ជាពិសេស ការចូលរួមដ៏សកម្មនិងមិនចេះនឿយហត់របស់សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ក្នុងការផ្តល់ការគាំទ្រជាប់ជាប្រចាំទាំងថវិកា សម្ភារ និងស្មារតី ជួយដល់ប្រជាពលរដ្ឋក្រីក្រ អ្នករងគ្រោះទូទៅ ដោយឡែកប្រជាពលរដ្ឋដែលកំពុងរងគ្រោះដោយផ្ទាល់ និងដោយប្រយោលពីការរាលដាលនៃមេរោគអេដស៍និងជំងឺអេដស៍នៅទូទាំងប្រទេស។

មុននឹងបញ្ចប់ ខ្ញុំព្រះករុណា ខ្ញុំសូមអនុញ្ញាត ថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍គ្រប់លំដាប់ថ្នាក់ អង្គការសហប្រជាជាតិ ដៃគូអភិវឌ្ឍ មូលនិធិសកល សង្គមស៊ីវិល ផ្នែកឯកជន សិល្បករ សិល្បការិនី ដែលមានតំណាងជាអគ្គរដ្ឋទូតសុច្ឆន្ទៈសម្រាប់ការងារប្រយុទ្ធនឹងជំងឺអេដស៍ បណ្តាញអ្នកផ្ទុកមេរោគអេដស៍ បណ្តាញក្រុមប្រជាជនគន្លឹះ និងក្មួយៗយុវជនទាំងអស់ព្រមទាំងប្រជាពលរដ្ឋទូទៅ ដែលបានចូលរួមចំណែកយ៉ាងសកម្មក្នុងការសម្រេចបាននូវសមិទ្ធផលជាទីមោទនៈជូនប្រទេសកម្ពុជានាពេលនេះ។

ជាទីបញ្ចប់នេះ ខ្ញុំសូមប្រសិទ្ធពរជ័យបវរមហាប្រសើរជូន **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** សូមប្រកបដោយសុខភាពល្អបរិបូរណ៍ កម្លាំងខ្លាំងក្លា ប្រាជ្ញាឈ្លាសវៃ សូមបន្តចូលរួមដឹកនាំនាវាកម្ពុជាឱ្យចាកផុតពីគ្រោះគំរាមកំហែង ដោយសារមេរោគអេដស៍និងជំងឺអេដស៍។

ខ្ញុំសូមជូនពរ ឯកឧត្តម លោកជំទាវ លោក លោកស្រី តំណាងដៃគូអភិវឌ្ឍ តំណាងអង្គទូតភ្ញៀវជាតិ អន្តរជាតិ និងក្មួយៗទាំងអស់ សូមប្រកបនូវពុទ្ធពរទាំងឡាយបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

ខ្ញុំសូមថ្លែងនូវការកោតសរសើរចំពោះគណៈកម្មការរៀបចំអង្គពិធី ដែលបានរៀបចំទិវានេះឱ្យប្រព្រឹត្តទៅដោយរលូន និងប្រកបដោយជោគជ័យ។

សូមអរគុណ។